**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២៥៩.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៤.១៩៤,២៨៦២ ហិកតា នៅស្រុកឈូក ខេត្តកំពត ក្នុងនោះ កាត់ចេញ ពីគម្របព្រៃឈើឆ្នាំ ២០០២ និពីដីសម្បទានក្រុមហ៊ុន ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនិងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៥៧លស. លេខ ២៥៨លស លេខ ២៦៣លស ២៦៤លស និងលេខ ២៦៦លស ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៤.១៩៥,២៨៦២ ហិកតា ដែលក្នុងនោះ (១) ទំហំ ១.៧៣៤,៧០៦៧ ហិកតា កាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ (២). ទំហំ ១៧៧,៦០១១ ហិកតា ពីក្រុមហ៊ុន WORLD TRISTA ENTERTAINMENT (CAMBODIA) Co.,Ltd (៣).ទំហំ ២៨៥,៨៨៨៦ ហិកតា ពីក្រុមហ៊ុន CAMTREE CORPORATION (៤). ទំហំ ១.៩៩៦,៨៨៩៨ ហិកតា ពីក្រុមហ៊ុន FIRST BIO-TECH AGRICULRAL (CAMBODIA) Co.,Ltd ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៣.៥៣៥,៧៥០៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែង និងទំហំ ៦៥៨,៥៣៥៨ ហិកតា រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកឈូក ខេត្តកំពត ដែលមានទំហំ និងស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ៥៥,៨៣៥២ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៥៤,៨៥៣៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០,៩៨១៥ ហិកតា រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិទូល ឃុំល្បើក

- ផ្ទៃដីទំហំ ១៧៥,០៩៤០ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១៧១,៣៦៨១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣,៦៧៥៩ ហិកតា រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិត្រពាំងបី ឃុំត្រពាំងបី

- ផ្ទៃដីសរុបទំហំ ១.៥៨០,៨៩៩៦ ហិកតា ក្នុងនោះ (១). ទំហំ ១.៤០៣,២៩៨៥ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង(២). ទំហំ ១៧៧,៦០១១ ហិកតា កាត់ចេញពីក្រុមហ៊ុន WORLD



p

TRISTA ENTERTAINMENT (CAMBODIA) Co,. Ltd ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មទំហំ ១.២៨៨,០១០៨ ហិកតា សិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៩២,៨៨៨៨ ហិកតា រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិទូលដូនី្ត ឃុំត្រពាំងភ្លាំង

- ផ្ទៃដីសរុបទំហំ ៧៥៣,៧៦៦០ ហិកតា ក្នុងនោះ (១). ទំហំ ១០០,៥២៩០ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ (២). ទំហំ ២៨៥,៨៨៨៦ ហិកតា ពីក្រុមហ៊ុន CAMTREE CORPORATION (៣). ទំហំ ៣៦៧,៧៨៨៨ ហិកតា ពីក្រុមហ៊ុន FIRST BIO-TECH AGRICULTURAL (CAMBODIA) Co,. Ltd ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ៦៨៩,៣០៣៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១០៩,៤៦២៧ ហិកតា រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិជ័យសេនា ឃុំតាកែន

- ផ្ទៃដីទំហំ ១.៦២៨,៧៨១៤ ហិកតា កាត់ចេញពីក្រុមហ៊ុន FIRST BIO-TECH AGRICULTURAL (CAMBODIA) Co,.Ltd ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មទំហំ ១.៣៧៧,២១៤៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៥១,៥២៦៩ ហិកតា រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិគេជោក្បាលដំរី ឃុំគេជោអភិវឌ្ឍន៍

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ឧបសម្ព័ន្ធទី២ ឧបសម្ព័ន្ធទី៣ ឧបសម្ព័ន្ធទី៤ និងឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១.៧១៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅខេត្តកំពត ស្រុកឈូក នៅក្នុងភូមិ ឃុំដូចខាងក្រោម៖

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២១ គ្រួសារ នៅភូមិទូល ឃុំល្បើក
-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩៦ គ្រួសារ នៅភូមិត្រពាំងបី ឃុំត្រពាំងបី
-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៧៨ គ្រួសារ នៅភូមិទូលដូនី្ត ឃុំត្រពាំងភ្លាំង
-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៧ គ្រួសារ នៅភូមិជ័យសេនា ឃុំតាកែន
-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨១៦ គ្រួសារ នៅភូមិគេជោក្បាលដំរី ឃុំគេជោអភិវឌ្ឍន៍។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។



p

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*



p